**ក្រុមប្រឹក្សារដ្ឋ/រដ្ឋសភា**

**ក្រឹត្យ/ច្បាប់/២១ ក្រ/១៥ កុម្ភៈ ១៩៩១/**

## ស្តីពីការបង្កើតពន្ធប្រថាប់ត្រា

## ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា

- បានឃើញ ច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨២

## សំរេច

ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតពន្ធប្រថាប់ត្រា ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩១ នាសម័យប្រជុំសាមញ្ញលើកទី២០ នីតិកាលទី ១។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១

## ច្បាប់

## ស្តីពីការបង្កើតពន្ធប្រថាប់ត្រា

**មាត្រា១:** ត្រូវបានបង្កើតពន្ធប្រថាប់ត្រា។

**មាត្រា២:** ពន្ធប្រថាប់ត្រាត្រូវបានអនុវត្តលើការផ្ទេរកម្មសិទ្ធិតាមរូបភាពលក់ទិញ :

- ផ្ទះ និងដីសង់លំនៅដ្ឋាន ៦ភាគរយ

- រថយន្តគ្រប់ប្រភេទ ៤ភាគរយ

- ម៉ូតូគ្រប់ប្រភេទ ២ ភាគរយ

- ទូក កាណូត កប៉ាល់ សាឡង់ ២ភាគរយ

**មាត្រា៣:** ចំណូលដែលបានមកពីពន្ធប្រថាប់ត្រា ត្រូវបង់ចូលថវិការដ្ឋ។

**មាត្រា៤:** តំណាង ឬភ្នាក់ងារអាជ្ញាធរណា ដែលបង្ខំទារ ឬទទួលយកប្រាក់ពន្ធប្រថាប់ត្រា ដែលគ្មានចែងក្នុងច្បាប់ ឬដែលលើសពីការកំណត់ក្នុងច្បាប់ត្រូវផ្តន្ទាទោសៈ

១- ដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើស មានចំនួនតិចជាង ១០.០០០៛ "មួយម៉ឺនរៀល"។

២- ដាក់ពន្ធនាគារពី ៥ឆ្នាំដល់ ១០ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើស មានចំនួន ១០.០០០៛ "មួយម៉ឺនរៀល " ដល់ ១០០.០០០ "មួយសែនរៀល"

៣- ដាក់ពន្ធពន្ធនាគារពី ១០ឆ្នាំ ឡើងទៅរហូតដល់អស់មួយជីវិត បើកំរៃដែលបានមកពីអំពើល្មើស មានចំនួនលើសពី ១០០.០០០៛ "មួយសែនរៀល" ឡើងទៅ។

**មាត្រា៥:** បែបបទនៃការប្រថាប់ត្រា និងបែបបទនៃការប្រមូលពន្ធប្រថាប់ត្រាត្រូវកំណត់ដោយអនុក្រឹត្យ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តនៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ១៩៩១ នាសម័យប្រជុំលើកទី២០ នីតិកាលទី ១។

ភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១